Khmer Story Lovers

# ឃាតកម្មៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៩៩ ជីឡូត៍លេខ ២៥៤ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គឹមសាន

តម្លៃ ២៥៛

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

«មាតុភូមិ»

ភ្នំពេញ

លេខ ៣២

តៅហៃស៊ីឆ្លើយរបៀបមនុស្សខ្ជិលច្រអូស:

-យើងមានជម្ងឺប្រចាំកាយយូរឆ្នាំណាស់មកហើយ, ខេះៗ... ស៊ើរស្លាប់ស៊ើររស់, យើងធុញទ្រាន់ណាស់.. បើលោកស្រីចង់សម្លាប់សូមអញ្ជើញមក!

កាវសានលាងជីស្រែកសន្ធាប់:

-ហ៊ឹះ! ឯងមិនសមជាអ្នកកាហានក្នុងពិភពគុនទេ! ម៉េចបានប្រើកាតព្វកិរិយាបែបញ្ញើរ ជាមួយយើង ? បើមិនព្រមនិយាយ, ត្រូវទៅហៅអាឆ្កែឥតពូជ ត្រកូលស៊ុ ចេញមក, យើងសួរវាម្តងទៀត ។

លោកស្រីជីនប្រាសថា តៅហៃស៊ីពាល់ខ្ញុំ មានការពិសោធន៍និងសិល្បគុណច្រើនណាស់ ប្រយុទ្ធមិនឈ្នះទេ ព្រោះគ្នាគាត់គឺមានចំនួនតិច, នាយក្រុមស៊ុជាក្មេងពោះម៉ាយនិយាយតាមត្រង់ គឺគាត់អាចមើលបុគ្គល និងកាតព្វកិរិយាយល់ខុសវៃ ៗ ស្រាប់តែនាយត្រកូលឈិនឈុនជីដែលឈរក្បែរតៅហៃស៊ីសើចហាស ៗ ឆ្លើយជំនួសលោកគ្រូតៅថា :

-សូមជំរាបលោកស្រីតាមត្រង់ចុះ លោកនាយក្រុមត្រកូលស៊ុចូលចិត្តស្រី ៗ មែន, តែលោកចូលចិត្តនារីក្មេងខ្ចី ស្អាតស្អក ល្អូន សំដីទន់ភ្លន់ទេ ។ ចំពោះលោកស្រីវិញ, ប្រហែលជាគាត... ហា...

សំដីនេះមានន័យប្រមាថមាក់ងាយលោកស្រីពេកហើយ មានន័យថាលោកស្រីចាស់ សំដីមិនពីរោះ ទើបលោកនាយក្រុមស៊ីមិនរបតី ។ ទីនតុនសើចញាញស្ញូរពេច ៗ ;

— បងស្រីការស្អាតណាស់តើ, បងស្រឡាញ់គាត់ទេ ?

ស៊ីផានជ្រួញចិញ្ចើម :

— កុំនិយាយផ្ដេសផ្ដាស, ប្រយ័ត្នគាត់ចោលកាំបិតមកណា !

— បើគាត់ចោលកាំបិតមកចាក់ខ្ញុំ, បងឯងជួយខាងណា ?

ស៊ីផានញញឹម :

— ខ្ញុំជួយលោកស្រីការ, មិនជួយអូនឯងទេ ។

ទីនតុនលូកដៃប្រុងមួលស្លឹកត្រចៀកនាយតែមាណពជំនិតខ្លួនទាន់ចាប់ដៃខាងក្រោយជាប់ ។ ពេលអ្នកទាំងពីរប្រឡែងគ្នានោះ , លោកស្រីការសានលានជើងនឹងនេះឆ្លួលលើកដៃចោលកាំបិតស្នៀតបីដើម តម្រង់ឈិនឈុនជីភ្លាម ។ នាយត្រួតឈិនគេចផុតទាំងបីរ៉ះសើចហេសៗ:

—ទោះលោកស្រីត្រូវការខ្ញុំកំសត់ប្រយោជន៍ដែរ, ខ្ញុំមិនព្រមទេ !

លោកស្រីខឹងសឹងក្អួតឈាម, លំផងកឹងពោលឃាត់ :

—ឈប់សិន, កុំអាលប្រយុទ្ធគ្នា ។

តែលោកស្រីអត់ទ្រាំមិនបានទេ, គាត់ដកកាំបិតស្នៀតចោលកាន់តែញាប់ឡើងៗ ... ឈិនឈុនជីគេចផុតពីកាំបិតប្រាំមួយ ដល់កាំបិតទីប្រាំពីរគាត់គេចមិនផុតត្រូវស្មារតឹប ! កាំបិតហោះទៅត្រូវជើងស្តាំនាយត្រួតចន់ជង្គង់ជួលគ្រប ! លោកស្រីការសានលានជីសើចចំអក :

— មិនបាច់លុតជង្គង់សុំទោសទេ !

ឈិនឈុនជីខឹងណាស់, ដកកាំបិតចោលសំដៅទៅភ្លាម, ហ្វុងលាងលើកវាំពាក់វង់កាត់ដែរ ។ មើលទៅច្បាស់ជាកើតការប្រយុទ្ធដ៏កាចរមិនខានស្រាប់តែស៊ីផានស្រែកខ្លាំង ៗ:

— កុំប្រយុទ្ធគ្នា ! កុំប្រយុទ្ធគ្នា . . . សុំឃាត់ ! អស់លោកខាងលាវតុងចង់រកខ្ញុំឬ ? ខ្ញុំមកហើយ !

ពេលផងជឹកដៃទីនតុនលោតចេញពីក្រោយផ្ទាំងថ្មផង , ឈិនឈុនជីនិងហ្វុងលានដកខ្លួនថយមួយរំពេច ។ ពលសេនាក្រុមឈានលួទាំងអស់ស្រែកហៅក្រញៀវលំទុនកាយគោរព :

លោកនាយក្រុមអញ្ជើញមកដល់ហើយ !

អ្នកក្លាហានណាវ៉ុងក្ទក់ព្រឺតគ្រប់គ្នាងាកមើលស៊ីផានម្តងទៀតឃើញបុកពារអើអាប សមធ្វើនាយក្រុមដែរ, សមាជិកក្រុមឈានល្អទាំងអស់ក៏មានអាកប្បកិរិយាត្រឹមត្រូវមិនមែនធ្វើពើប្តូរកូនក្បាលដែរ ។ គេនឹកថា:

- លោកមានគុណលើយើងនៅក្នុងមែន, តែខ្ញុំនឹងពូកែណាស់លោកប្រាប់ពួកយើងថាត្រកូលស៊ីដែរតើ, ម៉េចយើងមិនចាប់ភ្លឹក?

ការសានណានដីពោលមុនគេ :

- លោក . . . លោកមានគុណត្រកូលស៊ី . . . លោកជានាយក្រុមឈានល្អពិតមែនឬ ? បើដឹងមុននឹងចឹង យើងខ្ញុំមិនហ៊ានមិនជឿឡើយ, សូមអភ័យទោស ។

ស៊ីផានសើចញញឹមងាកទៅប្រាប់ពៃហៃស៊ី :

- លោកគ្រូពៃ, យើងមិនស្មានបានជួបគ្នានៅទីនេះសោះហ្ន៎ ! អស់លោកខាងណោះជាមិត្តភក្តិខ្ញុំដែរ, សូមកុំឈ្លោះតាស់ទែងគ្នា ។

ពៃហៃស៊ីត្រេកអរដោយឃើញមាណពក្រឡប់មកវិញ កំភ្លេចរឿងតាស់ទែងគ្នាអម្បាញ់មិញអស់ ព្រោះគាត់គ្មានគំនុំអ្វីជាមួយអ្នកស្រុកណាវ៉ុងនោះ ។ គាត់លំឱនកាយតប :

- បើបានលោកនាយក្រុមអញ្ជើញមកហើយ, សូមលោកចាត់ចែងរឿងរ៉ាវនេះចុះ ។

ការសានណានដីពោល:

- ពួកយើងបានជឿតាមការឃោសនាអកុសលថាលោកបង់តុងហ្វាងត្រូវគេសម្លាប់ហើយ ទើបសុខចិត្តធ្វើកិច្ចសន្យាជាមួយក្រុមឈានល្អ, យើងឥតនឹកស្មានថានាយក្រុមថ្មីជាអ្នកមានគុណសោះ ! លោកមានគុណក្លាហានអង់អាចចក្ខុល្អថែបង្កើត ពិតជាមិនប្រព្រឹត្តអំពើមិនគប្បីចំពោះលោកបង់តុងហ្វាងទេ ។ នេះគឺប្រាកដជាលោកបង់តុងមើលឃើញយល់ត្រូវថាលោកមានគុណពូកែអង់អាចចរិយាសុភាពត្រឹមត្រូវជាង លោកបានជាប្រគល់តំណែងជូនដូច្នេះ ។ តើឥឡូវលោកបង់តុងហ្វាងសុខសប្បាយឬទេ ?

ស៊ីផានមិនដឹងធ្វើយ៉ាងម៉េចក៏បែរទៅរកពៃហៃស៊ីសួរយោបល់:

-លោកបង់តុងហ្វាង ...

Khmer Story Lovers



តៃហេស៊ុយល់ចិត្តនាយក្លាម ទើបតបថ្នូស:

-លោកនាយក្រុមតុនហ្វាង ស្លាក់ក្នុងព្រៃភ្នំស្លាស្ងាត់មិនព្រមជួបអ្នកណាទេ ។ បើពុំនោះសោតយើងនាំអស់លោកទៅជួបគាត់ហើយ ។

ហ្វានយីហៃបន្ទន់កាយពោលថា :

– អម្បាញ់មិញពួកយើងបានបញ្ចេញកាយវិការយា និងពាក្យសំដីគ្រោតគ្រាតខ្លះ សូមលោកគ្រូពៃមេត្តាអភ័យទោសឲ្យខ្ញុំបាទផង ។

គាត់បន្ទន់កាយគោរព រួចពោលបន្ត:

ប៉ុន្តែពួកយើងមានការទាក់ទងជិតស្និទ្ធជាមួយលោកបងតុង ហ្វាងណាស់ មិនដូចមិត្តភក្តិធម្មតាទេ, យើងខ្ញុំនាំគ្នាតាមរកពីឆ្ងាយដើម្បីជួបមុខគាត់ផ្ទាល់សូមលោកមានគុណជួយធ្វើអន្តរាគមន៍ផង, លោកគ្រូពៃថា លោកបងតុងហ្វាងមិនចង់ជួបអ្នកក្រៅ តែ. . .យើងខ្ញុំមិនមែនអ្នកក្រៅទេ ។

ពោលចប់គាត់សម្លឹងមុខស៊ុផានមិនដាក់ ។ អ្នកកម្លោះសួរពៃហៃស៊ុ:

– លោកតុងហ្វាងនៅជិតៗនេះទេដឹង ? អស់លោកមកពីណាវតុងចង់ជួបគាត់ហើយមិនបានជួបវិញក្រែងគេអស់សង្ឃឹមណា ! លោកគ្រូពៃ ។

ពៃហៃស៊ុពិបាកចិត្តក្រៃលែង ស្តាប់សំដីលោកនាយក្រុមស៊ុដូចស្តាប់បញ្ជា, ជាពិសេសលោកនាយក្រុមហាក់ភ្លេចរឿងចាស់ៗសរលីងពោលពាក្យបែបនេះកណ្តាលហ្វូងដូច្នេះ រករំពឹងលោកឯណាបាន ។

គ្រូពៃពោលបង្វែងដាន :

– រឿងនេះមានការទាក់ទងវែងឆ្ងាយណាស់, និយាយមិនងាយចប់ទេ ។ អស់លោកអញ្ជើញមកពីឆ្ងាយនឿយហត់ណាស់, សូមអញ្ជើញទៅជំរំយើងខ្ញុំ ដប់លៀងឲ្យបានសប្បាយរីករាយសិនឬ ? ទីតាំងក្រុមឈានល្មួនៅមិនឆ្ងាយពីទីនេះប៉ុន្មានទេ ។

ខណ្ឌទី ៣០

## អាថ៌កំបាំងនៃនាយក្រុម

ស៊ុផានសួរដោយឆ្ងល់:

– ទីតាំងរបស់យើងនៅជិតនេះឬ ?

តៃហាស៊ីមើលមុខលោកនាយក្រុមទឹកចិត្តថា:

– ជម្ងឺល្ងើធ្វើទុក្ខលោកនាយក្រុមទៀតហើយ ។

គាត់ប្រញាប់តបភ្លាមថា:

– យើងធ្វើដំណើរទៅខាងកើតប្រហែលជាងហាសិបយោជន៍ដល់ហើយសូមលោកនាយជ្រាប ។

ស៊ីផានបែរមើលមុខទីងតុងធ្វើមិនដឹង ។ ទីងតុងស្រស់សំណើចណាស់, លើកដៃខ្ទប់មាត់ភ្លាម ។ រីឯគហ្វានឃើញ ដែលចង់បានតំណែងនាយក្រុមតុងហ្វានណាស់ក៏យល់ព្រមពោលថា:

– បានជាមកដល់ដំណាងហើយ, គួរទៅលេងទីតាំងអស់លោកមួងជាការល្អម៉្យាងដែរ ។

ទាំងអស់គ្នាចាប់ផ្តើមចេញដំណើរឆ្ពោះទៅទិសខាងកើត រហូតទៀបភ្លឺទើបដល់ទីតាំងក្រុមឈានល្បួ នៅទីនោះមានសមាជិកជាច្រើនចេញមកទទួលគួរណាវ៉ុងគ្រប់រូបយ៉ាងគួរសម ។

ស៊ីផានដឹងទីងតុងដើរចូលបន្ទប់ខ្ទនភ្លាម ។ តាយផានឃើញលោកនាយក្រុមត្រឡប់មកវិញ នាងរីករាយណាស់ ។ រីការដែលឃើញនាយនាំមាត់ម្នាក់មកផងជាការធម្មតាចំពោះតាយផានទៅវិញព្រោះនាងធ្លាប់ជួបប្រទះច្រើនដងណាស់ហើយ ។ នាងនឹកតែក្នុងចិត្តថា :

– ទើបនឹងជាសះស្បើយសោះ, គណ្ហាវីបរើឡើងវិញភ្លាម ។ ថ្ងៃមុនយើងស្មានថា លោកឈឺធ្ងន់ភ្លេចភ្លាំងស្មារតីលោកកែគំនិតខ្លះ, ពេលនេះឥតសង្ឃឹមទេ, ទាល់តែថ្ងៃរះពីខាងលិច ទើបមានផ្លូវ ។

បន្ទាប់ពីលប់លាងមុខស្អាតបាត, ស៊ីផានអង្គុយផឹកតែ ស្រាប់តែតៃហាស៊ីពោលពីក្រៅបន្ទប់ថា :

– តាយផាន! សុំជម្រាបលោកនាយក្រុមថា ខ្ញុំសុំជួប ។

មាណពមិនចាំឲ្យតាយផានមកប្រាប់ ក៏ក្រោកទៅបើកទ្វារសួរភ្លាម :

– លោកគ្រូពេលមកព្រឹកណាស់, ខ្ញុំកំពុងចង់សួរលោកគ្រូពីរឿងលោកនាយក្រុមតុងហ្វាននោះណា! រឿងរ៉ាវយ៉ាងម៉េចខ្លះ ?

– បាទៗ, សូមលោកនាយក្រុមអញ្ជើញមកតាមខ្ញុំ ។

តៃហាស៊ីនាំមាណពដើរកាត់សួនច្បារដល់តូបមួយចំកណ្តាល ទើបអញ្ជើញលោកនាយក្រុមអង្គុយ

ស្រួលបួលឡើងសួរ :

–តាំងពីលោកនាយក្រុមផាសនេះស្ងៀមពីពេលចប់រឿង លោកនាយពិតជាក្មួយរៀនចាស់ ដែរលើន មែនឬ ?

ស៊ីផានរ៉េបជំនុំថា ក្រុមណារចណ្ណលើកនាយឲ្យធ្វើនាយក្រុមមិនមែនមានបំណងល្អទេ ។ ផុតពុក្កាយនាយបានរកញែកសត្វគ្រប់ហើយជាកេឲ្យនាយធ្វើគ្រោះកេសត្វជំនួសគេ ក្នុងពេលណាមួយ មិនខានគឺគេប្ដូរជីវិតនាយក្រុមដើម្បីជួយការពារជីវិតសមាជិកទាំងអស់ ។

ប៉ុន្តែបារម្ភគនិកថាតែហ៊ុសស៊ីគួរសមតិចតែពេកនាយណាស់ ។ ម្យ៉ាងទៀតពេលនាយឈឺថ្កាត់ មួនក្តៅមួនត្រជាក់សម្ងួបសម្ងំនោះ មានតែលោកគ្រូពេទ្យនេះហើយ ដែលបំរើក្បាន់ជួយព្យាបាលនាយឲ្យបានធូរស្រាលមួយគ្រាៗ, បានសេចក្តីថាគាត់មានគុណលើនាយមួយចំណែកធំ ហើយនឹងទៅទស្សនគ្រូនឹង ។ ក្រៅពីគាត់ខ្មាសអៀនមិនយាយបន្ទរការពិត ។ ម្យ៉ាងទៀតនាយក្មួចរៀនចាស់មែនត្រូវសួរលោកគ្រូពេទ្យឲ្យច្បាស់ក្លាស់អំពីការលួម្យ៉ាងដែរ ទើបតបថា :

–មែនហើយ ! ហេតុនេះសុំលោកគ្រូជួយរៀបរាប់តាំងពីដើមដល់ចប់ឲ្យខ្ញុំស្ដាប់ផងមើល !

តៃហ៊ុសស៊ីក្អកខេះ ១ ហើយក្រោមបាយកសរម្មង់ដើមផ្ដើមរៀបរាប់ :

– លោកនាយក្រុមបាស់ហ្វើនមានឈ្មោះថា គុជ ហ្វាន់ ហ៊ុង មកស្រុកខ្មែរយើងកាលធាតុក្រញាំប្រាំពីរ, ហើយត្រូវជាគ្រូមាររបស់លោកនាយផងណា ! ត្រង់នេះលោកនាយចាំទេ ?

ស៊ីផានសួរទាយន្ទរ :

– គ្រូមាខ្ញុំផង ? មើល .. មើលខ្ញុំមិនដឹងសោះ ! តើគាត់ជាបក្សពួកក្រុមណាដែរ ?

–លោកនាយគុជ ហ្វាន់ ហ៊ុងមិនដែលរំឭកប្រវត្តិលោកប្រាប់យើងខ្ញុំទេ ឯយើងខ្ញុំរាសេនាក៏មិនហ៊ានសួរដែរ ។ បីឆ្នាំមុននេះ, លោកនាយបានទទួលបញ្ជាពីលោកគ្រូ...

– ខ្ញុំឬ ? ខ្ញុំបានទទួលបញ្ជាពីលោកគ្រូ ? គ្រូខ្ញុំមួយណាទៅ !

លោកគ្រូពេទ្យតៃរក្សាឈ:

– ជម្ងឺលោកនាយធ្ងន់នេះធ្ងន់ពេកណាស់, សូម្បីតែគ្រូក៏ភ្លេចឈ្មោះដែរ ។ គ្រូរបស់លោកនាយមិនដឹងជានរណាទេ ... កាលមុនពួកយើងរាល់ផ្ទាំងខាងក្នុងទឹកកកឲ្យនាយហៅថាទប្រកាន់លោកនាយជាសិស្សក្នុងទឹកកកដែរ, រឿងនេះយើងខ្ញុំនៅងឿងឆ្ងល់ណាស់ ។

គ្រូពេលយប់បន្តិចរង់ចាំឲ្យស៊ីផានប្រាប់គាត់មុន ។ មាណពសញ្ជាតិតែមួយសន្ទះទើបតោរ ម្នាក់ឯង:

- លោកគ្រូខ្ញុំ ! . . . ខ្ញុំបានសុំយាយស៊ីវានគ្រូបព្រះអាទិត្យធ្វើត្រាមែន, តែរឿងនេះទើបកន្លងហួសប្រហែលមួយខែប៉ុណ្ណោះ ។

នាយលើកដៃទះក្បាលប៉ុកៗគ្រេះគ្រះឃើញថា រឿងការរំលងមានខាងបញ្ចាក់រឿងវិញបាន ក៏មិនស៊ីនឹងរឿងដែលគេរំពឹកប្រាប់នាយសោះ ។ មាណពប្រមូលគំនិតគ្នាសាកសួរទៀត :

- ខ្ញុំទទួលបញ្ហាពីលោកគ្រូថាម៉េចខ្លះ ?

-លោកនាយទទួលបញ្ហាគ្រូពីទៀមករកនាយក្រុមឈានល្អនាមគុន ហ្វានហ៊ុន ជួយប្រាប់ផ្ទៃផ្ទាំងប្រទេសនាគបានទូរគ្រាប់ក្រោយទីនេះដែរ ។ បន្ទាប់ពីនានក្រុមឈានល្អយើងបានដឹងរឿងហោកមួយយ៉ាងសំខាន់នឹងបញ្ហាផ្ទាកបញ្ញាមរណៈ ។ លោកបាននៅចាំរឿងដែលគ្នានេះដែរ ?

-ខ្ញុំដឹងរឿងផ្ទាកបញ្ញាមរណៈដែរ តែការដែលក្រុមឈានល្អដែលគ្នានោះខ្ញុំគ្មានឃើញអ្វីសោះទេ ។

-កាលណោះយើងបើកសម័យប្រចាំឆ្នាំ មានជាយក្រុមឈ្នះនៃក្រុមប៉ោងទាំងអស់មកជួបជុំគ្នាក្នុងដំណើរពិភាក្សាបញ្ហាពិសេស ។ ថ្ងៃនោះមានគ្នាយើងម្នាក់បានរំពឹកថាក្រុមហោនល្អលក្ខណៈសល់ហើយ គាត់តែលើព្រលែងឃើញផង ។ គឺពីធ្លាប់ភាគមុខ បញ្ញាមរណៈ បង្ហាញរូបរាងក្នុងពិភពលោក, ក្រុមយើងបាត់ប្រាប់ដោយមិនដុតទេ ។ ព្រោះនោះសួរអន្តរប្រជុំថាត្រូវធ្វើយ៉ាងណាគោរពគត់គ្នាទុកជាមុន កុំចាំដល់ពេលប្រជុំប្រញាប់នាំពិបាក ។

ស៊ីផានដឹកក្បាល :

- មែនហើយ ! ដរាបណាបញ្ញាមរណៈលេចរូបវាវិញមក, នាយក្រុមនីមួយៗមិនព្រមទទួលបញ្ហាទៅផប់លៀនបបរខែកត្តិក, មនុស្សទាំងអស់ក្នុងបក្សត្រូវទទួលគ្រោះថ្នាក់ដល់ជីវិតឥតសល់ម្នាក់ ។ ទិដ្ឋភាពដ៏គួរណោចអាថ៌កំបាំងរឿងបញ្ញាមរណៈ ខ្ញុំឃើញផ្ទាល់ភ្នែកហើយ !

ពៅហៃសុំសួរដោយឆ្ងល់ :

- លោកនាយក្រុមឃើញផ្ទាល់ភ្នែក ?

-ហ៊ឺ ! ខ្ញុំបានប្រាប់ហើយថាខ្ញុំមិនមែនជានាយក្រុមរបស់អស់លោកទេ ។ ប៉ុន្តែរឿងស្លាប់ទាន់

Khmer Story Lovers



ហន់គឺខ្ញុំបានឃើញផ្ទាល់ភ្នែកមែន, ក្រុមត្រីហោះមួយក្រុមឬកផែកមួយ ស្លាប់គ្មានសល់ម្នាក់ទេ !

ដំណឹងក្រុមត្រីហោះនិងក្រុមឬកផែកស្លាប់យ៉ាងអាណោចអាធ័ម បានលេចឮដល់ក្រុមឈានល្បួផែរ, ពៃហៃស៊ុងកដង្ហើមធំពោលថា:

– យើងខ្ញុំបារម្ភចំពោះរឿងនេះតាំងពីយូរយារណាស់ហើយ ។ ព្រោះហេតុនោះឯងបានជាក្នុងសម័យប្រជុំលោកនាយត្រួតត្រកូលហៀង ស្តីរឿងបញ្ញាមរណៈ ។ អង្គប្រជុំមិនអាចពោទគាត់បានថាបំភិតបំភ័យគ្នីគាទេ ។ មិនដឹងហេតុអីលោកនាយគុងហ្វាងគ្រាន់តែឮភ្លាមក៏ខឹងច្រឡោតពោទនាយត្រួតហៀងថាម៉ាប៉ុបះបំបោរបំភ័យអ្នកក្រាល់គ្នា, ស្រែកបញ្ជាឲ្យចាប់នាយត្រួតហៀងទៅបំរុំឃាំងភ្លាម ។ យើងខ្ញុំបានជួយអង្វរគ្រប់ ៗ គ្នា លោកយល់ព្រមតែមាត់ទៅ, ដល់យប់អាធ្រាត្រប្រាប់តែគាត់ចូលទៅលួចសម្លាប់នាយត្រួតយ៉ាងស្ងាត់ ។ ស្អែកឡើងគាត់ផ្សាយដំណឹងថានាយត្រួតហៀងធ្វើអត្តឃាតហើយ !

– យី ! ម៉េចអ៊ីចឹង ? ក្រែងលោកនាយក្រុមគុងហ្វាង មានគំនុំនឹងនាយត្រួតរូបនោះទេដឹង ?

ពៃហៃស៊ុគ្រវីក្បាល :

– **មិនមែនទេ** , ការពិតគឺលោកនាយក្រុមគុងហ្វាង មិនចង់ឲ្យនរណារំលឹករឿងនេះតែម្តង !

ស៊ុផងាឧងក់ក្បាលដោយយល់ហេតុផលច្បាស់លាស់ ។ ត្បិតនាយមិនមែនល្ងង់ខ្លៅដូចគេស្មានឡើយគ្រាន់តែមិនដែលបានទាក់ទងជាមួយមនុស្សពិតិតាំងពីប៉ូន ហើយមិនដែលដើរត្រប់ច្រកល្ហកដូចអ្នកគុននិយមផងទាំងពួង ។ ប៉ុន្តែដោយបានដើរជាមួយប្តីប្រពន្ធស៊ុឈីងបួនដប់ថ្ងៃ, នាយចេះដឹងច្រើនទទួលការអប់រំពីទុងយូច្រើនលើសលប់ទើបនាយក្លាយខ្លួនជាអ្នកក្លាហានមួយរូប ចេះស្ទាបស្ទង់ចិត្តអ្នកដទៃយល់បានខ្លះៗ, ចេះនិយាយពាក្យគួរសមមិនឲ្យគេប្រកែកប្រកាន់ ។

នាយនឹកថា :

–លោកនាយក្រុមគុងហ្វាងដឹងខ្លួនណាស់ថាកាលណាទទួលបញ្ញាមរណៈ គាត់ត្រូវស្លាប់ពេលសាចពេលគួរក្នុងទឹកសមុទ្រ, បើគាត់មិនទទួលបញ្ញាក៏ត្រូវបូជាជីវិតផ្ទាល់ និងជីវិតសមាជិកទាំងអស់ផងម៉្លោះហើយគាត់មិនចង់ឲ្យនរណារំឭករឿងទាល់ច្រកនេះប្រាប់គាត់ឡើយ ។

ពេលនោះពៃហៃស៊ុពោលបន្ត :

-បងប្អូនទាំងអស់សុទ្ធតែដឹងថាគាត់សម្លាប់នាយក្រុកហៀនផ្ទាល់ដៃ, ហេតុនេះដល់ពេលឃើញផ្កាកបញ្ញាពិតជាគាត់មិនញញើតនឹងបូជាជីវិតបងប្អូនយើងក្នុងក្រុមឈានល្អទាំងមូលទេ ។ បងប្អូនយើងទាំងអស់បារម្ភក្នុងចិត្តណាស់ឥតហ៊ានហើបមាត់ថាដូចម្តេចឡើយ ។ ខណៈនោះហើយដែលលោកស្ទុះចេញទៅសួរគ្រូមា ...

ស៊ីផានក្អាក់ក្រញាង:

- ខ្ញុំ ? ខ្ញុំចេញទៅសាកសួរគាត់ឬ ?

- បាទ, ពិតហើយ ! កាលណោះលោកមានប្រសាសន៍យ៉ាងក្បោះក្បាយថា លោកគ្រូមា, លោកជាចាស់ទុំដឹកនាំក្រុមបក្សទាំងមូលត្រូវចេះពិចារណាវែងឆ្ងាយបន្តិច ដើម្បីសេចក្តីសុខនៃក្រុមឈានល្អផង ។ សេនាបញ្ញាមរណ ផិតចេញមកធ្វើប្រតិបត្តិការហើយ ! លោកនាយគ្រូគហៀនស្នើឲ្យយើងរិះរកមធ្យោបាយឬចាត់វិធានការការពារសេចក្តីសុខរួមជាការល្អប្រសើរណាស់, បើលោកគ្រូមាបង្ខំឲ្យគាត់ធ្វើអត្តឃាតក្រែងអ្នកឯទៀតមិនអស់ចិត្តណា ? ថ្ងៃនោះលោកនាយក្រុមគុងហ្វាងស្រែកជេរថា អាចង្រៃប៉ើមធំម្ល៉េះ ? ក្នុងជំរំក្រុមឈានល្អ, ឯងគ្មានសិទ្ធិនិយាយតវ៉ាទេ ! ក្រុមឈានល្អកើតឡើងដោយរូបយើងផ្ទាល់, បើត្រូវវិនាសសាបសូន្យទៅវិញក៏នៅក្នុងកណ្តាប់ដៃយើងដែរ ! អ្នកក្រៅគ្មានត្រូវការដឹងឮទេ !

សំដីលោកនាយក្រុមទាំងប៉ុន្មានធ្វើឲ្យបងប្អូនយើងព្រឺព្រួចជាអនេក ។ បន្ទាប់ពីនោះមកលោកបន្តទៅទៀតថាគ្រូមា, បើលោកមាដឹងថាទទួលបញ្ជាក៏ស្លាប់មិនទទួលក៏ស្លាប់ ម៉េចលោកមាមិនពិចារណាផង ? វាមានខុសគ្នាត្រង់ណា ? មិនព្រមទទួលគឺលោកមាទាញបងប្អូនទាំងអស់ឲ្យស្លាប់តាមសារបង់តែឥតបានប្រយោជន៍អ្វីដល់លោកគ្រូមាទេ ។ គួរតែគ្រូមាទទួលកុំរុញរាទើបសមជាអ្នកក្លាហាន ទើបបងប្អូនទាំងអស់គោរពជាទីសក្ការៈទៅថ្ងៃក្រោយ ។

ស៊ីផានស្តាប់ដល់នេះងក់ក្បាលមួយៗ :

- សំដីអស់នេះសមហេតុផលណាស់តែ . . . តែលោកគ្រូពៃភ្លាំ , ខ្ញុំគ្មានរ៉ាហាប៊ុនប្រសច និយាយពីកេះផល់ម៉ុំងទេ !

ពៃហស៊ីញញឹម:

- សូមលោកនាយក្រុមកុំដាក់ខ្លួនពេក ! នេះមកពីជម្ងឺលោកនាយក្រុមមិនជាដាច់ស្រឡះ ទើប

ខួរក្បាលមិនសូវភ្លឺស្វាងមែនទែន ។ ថ្ងៃក្រោយលោកនាយទីងប្រសប់និយាយបញ្ចេញសុទ្ធតែពាក្យពីរោះៗកុំថាឡើយត្រឹមមនុស្សក្នុងក្រុមបក្សយើង, សូម្បីអ្នកគុននិយមកំរកម្នាក់ណាមួយប្រៀបផ្ទឹមនឹងលោកនាយមិនបានដែរ ។

ស៊ីផានមិនទាន់អស់សង្ស័យសួរទៀតថា:

- មែនឬ? ដល់ខ្ញុំនិយាយចប់ទៅវាយ៉ាងម៉េច?

- បាទ, កាលណោះលោកនាយក្រុមគុនហ្វានឡើងមុខក្រហមងាំងទះតុផាំងៗ ស្រែកខ្លាំងៗ: ផាច់ៗ... ផាប់ចាប់កាត់ក្បាលចោរនេះមកឲ្យយើងភ្លាម! ប៉ុន្តែគាត់ស្រែកយ៉ាងណាក៏យើងមិនធ្វើតាមដែរ, យើងគ្រាន់តែមើលមុខគ្នាឡើងខ្សឹបតគំរើតសោះ ។ នាយក្រុមគុនហ្វាងរឹតតែខឹងឡើងឡើងទះតុផាំងៗ! ស្រែកទៀតថា អស្ចារ្យ! អស្ចារ្យមែន! ឯងរាល់គ្នាគិតជាមួយគាត់ក្រែនេះ ដើម្បីក្បត់យើងឬ? ល្អ! ពួកឯងរាល់គ្នានៅឲ្យស្ងៀម ចាំយើងសម្លាប់អានេះខ្លួនឯងផ្ទាល់

ស៊ីផានសួរដោយភ័យ:

- ចុះបងប្អូនយើងឃាត់គាត់ផងទេ?

តៃហៃស៊ីឆ្លើយ.

- ទេលោក! បងប្អូនយើងគ្រប់រូបគ្មាននរណាពេញចិត្តនឹងគាត់សោះ តែគេមិនហ៊ានចេញស្តី ។ នាយក្រុមគុនហ្វាងឃើញដូច្នេះក៏ដកក្រញាំនាគប្រាំបីលោតចេញពីកៅអីត្រវីក្រញាំនាគទៅលើលោកនាយ តែលោកនាយផ្លៀងខ្លួនគេចផុតយ៉ាងប្រសប់ ។ លោកនាយក្រុមគុនហ្វាងបញ្ចេញស្នៀតល្អផ្តាច់យ៉ាងណាក៏លោកនាយគេចផុតដែរ ។ កាលណោះលោកនាយឥតតបមួយស្នៀតឡើយ ព្រោះលោកនាយដៃទទេ ឯគុនហ្វាងមានក្រញាំនាគដ៏ល្បីល្បាញក្នុងដៃ ។ គ្រាន់តែលោកនាយគេចបានប្រាំពីរប្រាំបីស្នៀតឃើញថាជាការកម្រណាស់ទៅហើយ ។ ស្រាប់តែលោកនាយក្រុមគ្រូនីស្រែករំឭកថា លោកនាយក្រុម! សិស្សក្មួយលោកគេចបានប្រាំបីស្នៀតដោយឥតតដៃវិញទេណា! នេះជាកិច្ចគោរពលោកដែលជានាយក្រុមនិងជាគ្រូធំ ។ បើលោកនាយក្រុមវាយប្រហារសិស្សក្មួយបែបនេះតទៅទៀតអ្នកក្លាហានក្នុងលោកនឹកថាមប្រមាថ លោកនាយគ្រប់ម្នាក់ហើយ!

នាយក្រុមគុនហ្វាងស្រែកសន្ធាប់:

-អ្នកណាមិនឲ្យវាយតៃ ? ឈ្លើយ ! ពួកឯងបានជាផ្សៀងទៅលើវាហើយគប្បីជាញាត្រូវសម្លាប់ យើងមកទីនេះពេលលើកការប្តឹងនេះកុំនាយក្រុមម្តងឲ្យសមនឹងចិត្តគំនិតឃ្លាឯងដែលត្រូវតែយើងពេញចិត្ត !

ខាត់គាត់ស្រែកតៃដៃគាត់វាយលុកញាប់ឡើង .. មួយរំពេចនោះលោកនាយទទួលគ្រោះកាសព្វផ្លូនខ្នងក្លាម ប៉ែបរបៀសមិនផុតពីស្លាប់ក្រោមក្រញាំនាគនេះ ។ ក្នុងគ្រាប្រផុចញ៉ចនោះលោកនាយគ្រូកខានប្រែកឡើងថាលោកម្ចាស់ទិញស៊ីទទួលដាវ ! ហើយគាត់បោះដាវមួយជូនលោកនាយទុំ ; លោកនាយចាប់ដាវជាប់ហោតគេចពីក្រញាំនាគបីស្នៀតបែមទៀតទើបពោលទៅកាន់គ្រូមា តុងហ្វាងថា លោកគ្រូមា, ខ្ញុំបណ្តោយឲ្យលោកមាបញ្ចេញម្ហូស្នៀតហើយណា ! បើមិនព្រមឈប់ខ្ញុំទ្រាំលែងបាន ខ្ញុំវាយសងវិញឥឡូវហើយ ។ លោកនាយក្រុមតុងហ្វាងជះហឹង្សាតាមសរសៃចក្ខុហើយយានក្រញាំនាគណាន់វែបទស់ទៅលោកនាយទៀត ។

ពេលនោះគ្នាយើងប្រហែលម្ហូសាមសិបនាក់បានស្រែកកញ្ជ្រាលោកនាយថាតៃវិញទៅ ! វាយសងវិញទៅ ! កុំឲ្យគេសម្លាប់ទាន់ ! លោកនាយពោលក្លាមថា:

-សូមលោកគ្រូមាអត់ទោសណា !

ពេលហើយលោកនាយលើកដាវនេះគាត់យ៉ាងប្រញាប់ ។ ឆាកប្រយុទ្ធមានភាពកាចសាហាវណាស់, ជាពិសេសលោកតុងហ្វាងនិងលោកនាយមានយុទ្ធសិល្ប:និងកាយវិការប្រហាក់ប្រហែលគ្នាដូចបានហាត់រៀនក្នុងក្រុមតែមួយ ។ លោកប្រយុទ្ធគ្នាអស់ពេលមួយសន្ទុះធំនៅតែមិនទាន់ដឹងចាញ់ឈ្នះ តែពួកខ្ញុំដឹងថាលោកនាយមិនទាន់បញ្ចេញស្នៀតគុនដាវអស់ពីខ្លួនទេ ។

លោកនាយក្រុមតុងហ្វាងចេះតែវាយសម្រុកឥតសំចៃដៃ , ឥតត្រាប្រណី ទាល់តែលោកនាយទ្រាំមិនបាន ក៏សំដែងស្នៀតមួយយ៉ាងចម្លែក ប្រហាក់ប្រហែលនឹងស្នៀតប្រានទូកបណ្តោយទឹក ចាក់ត្រូវដៃស្តាំគាត់ធ្លាយិប - ឮសូរគ្រាវ ១ គឺក្រញាំនាគគាត់ជ្រុះធ្លាក់ដីអស់ , លោកដកដាវលោកថយក្រោយបីជំហានយ៉ាងរហ័ស , លោកតុងហ្វាងឈរស្លេចស្មារតីកណ្តាលហ្វូងពួកយើងមុខឡើងស្លាំងឥតឈាមមួយតំណក់ , ហើយគាត់គ្រោតគ្រាប់ភ្នែកសម្លឹងពួកយើងម្តងម្នាក់ ។

ពេលនោះទីប្រជុំស្ងាត់ស្ងៀមឈឹងពុំតែងដង្ហើមតឹងត្អួតនៃយើងរាល់គ្នា និងឈាមស្រស់ហូរតក់ៗពីមុខរបួស មួយសន្ទុះធំទើបលោកតុងហ្វាងពោលដោយអស់សង្ឃឹមថា ប្រសើរណាស់ៗ... ហើយគាត់បោះជំហានទៅក្រោយបាត់ ។ ពួកយើងនៅទីនោះមានចំនួនជាប់សាមសិបនាក់សម្លឹង

Khmer Story Lovers



តាមក្រោយគាត់ រហូតដុតកន្ទុយភ្នែកតែគ្នាទិនរណា ហ៊ានបើកមាត់ជាមួយឡើយ ។

លុះនាយក្រុមគុនញ្ញាណដើរចេញផុត យើងដឹងថាគាត់លែងហ៊ានមើលមុខត្រឡប់មកជួបពួកយើងវិញហើយ, ហើយចាប់ពីថ្ងៃនោះមកយើងគ្មានមេកោយដឹកនាំ ទើបយើងខ្ញុំសម្រេចចិត្តតែងតាំងលោកជានាយក្រុមក្នុងពេលនោះទៅ ។

កាលណោះលោកនាយបានពោលអះអាងយ៉ាងក្លៀវក្លាថា : ខ្ញុំបាទជាក្មេងគ្មានកេរ្តិ៍គ្មានឈ្មោះ ខ្វះសមត្ថភាព, តាមពិតមិនត្រូវទទួលភារៈដ៏ធ្ងន់នេះទេ ប៉ុន្តែខ្ញុំនឹកដល់ផ្ទាំងបញ្ជាមរណៈក្នុងពេលរាប់ឆ្នាំមុខក្នុងពិភពគុនរាជ័បឆ្នាំខាងមុខនេះឯង ។ ខ្ញុំសុខចិត្តទទួលតំណែងនេះជាបណ្តោះអាសន្ន, កាលណាសេនាធំពីរបញ្ជូនផ្ទាំងបញ្ជាមកដល់ខ្ញុំទទួលដោយឥតប្រកែកឡើយ, ខ្ញុំសុខចិត្តរ៉ាប់រងគ្រោះថ្នាក់ជំនួសអស់លោក ។

បងប្អូនទាំងអស់ស្តាប់ចប់ក៏ស្រែកហៅកញ្ច្រៀវព្រមគ្នា ហើយទទួលការគោរពលោកនាយក្រុមភ្លាម ។ សុំជំរាបលោកនាយតាមត្រង់ចុះ, លោកកេចក់យឈ្មោះលោកនាយក្រុមគុនញ្ញាណថ្ងៃនោះជាការដែលយើងខ្ញុំតក់ទឹកស្លាន់ចាល់តែសោះ ព្រោះហើយយើងគោរពស្រឡាញ់លោកនាយណាស់, ប៉ុន្តែបើលោកនាយមានយុទ្ធសិល្បៈទន់ខ្សោយក៏យើងនៅតែលើកលោកជានាយក្រុមដែរ ព្រោះលោកយល់ព្រមរំដោះទុក្ខពួកយើងដោយឥតរួញរា ។

ស៊ីផធានងក់ក្បាល:

-អឺចឹងបានជាខ្ញុំទៅណាម្តង១, អស់លោកចេះតែដើរតាមខ្លាចខ្ញុំមិនត្រឡប់មកវិញ !

តៅហស៊ុក្រហមមុខបន្តិច :

-តាំងពីលោកនាយក្រុមឡើងកាន់តំណែងមក, ព្រឹត្តការណ៍ទាំងអស់ដែលបានចាត់សុទ្ធតែត្រូវចិត្តយើងខ្ញុំ ព្រោះលោកនាយក្រុមតែងតែចំពោះយើងខ្ញុំខ្វះកំដោយ ។ យើងខ្ញុំនឹកដល់សន្តានចិត្តដ៏ល្អរបស់លោកនាយក្រុមដែលហ៊ានយកជីវិតមកការពារយើងខ្ញុំទើបយើងខ្ញុំកោតគោរពលោកជានិច្ច ។

ស៊ីផធានសញ្ជឹងគិតបន្តិចទើបសួរ :

-លោកគ្រូតៃ, រឿងដែលកន្លងហួសទៅនោះខ្ញុំភ្លេចអស់រលីងហើយ ហេតុនេះសុំលោកកុំលាក់នឹងខ្ញុំណា ! តើកាលមុនខ្ញុំប្រព្រឹត្តអំពើអ្វីខ្លះដែលមិនគប្បី ?

-បើនិយាយពីក្រុមបក្សយើងគ្មានទេ ។ ប៉ុន្តែធ្វើម៉េច ? លោកនាយក្រុមនៅក្មេង តែងចូលចិត្តការសប្បាយជាធម្មតាមិនត្រូវចាត់ទុកជាកំហុសឡើយ ។ ម្យ៉ាងទៀតនារីអស់នោះសុទ្ធតែស្ម័គ្រចិត្តមកកំដរលោកនាយដែរតើ, មិនដែលមានការបង្ខិតបង្ខំទេ ។ ក្រុមឈានល្អមានកេរ្តិ៍ឈ្មោះមិនសូវស្អាតស្អំពីមុនស្រាប់ ពោះបងប្អូនយើងបានព្រំណាំងប្រភេទនេះក៏យើងឥតយកជាការដែរ, គ្រាន់តែសើចលេងសប្បាយប៉ុណ្ណោះ ។

ស៊ីផានអង្គុយស្ដាប់បែកញើសជោកថ្ងាសនឹកថា ពោះលោកគ្រូពានិយាយព្រងើយយ៉ាងនេះក្ដីគង់នាយសាងបាបកម្មច្រើនណាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ។ មាណពខំរកនឹកមើល តើក្រៅពីចិន្តកុងនាយមានទាក់ទងឬលេងសើចជាមួយនារីណាផ្សេងទៀត ? នាយនឹកមិនឃើញសោះ ។ តៃហាស៊ីបន្ត :

– លោកនាយក្រុម, ខ្ញុំបាទចង់សុំជំរាបមួយម៉ាត់តែមិនដឹងជាសមឬមិនសម...

មាណពឆ្លើយភ្លាម :

- ហ៊ឺ ! ខ្ញុំកំពុងតែចង់ឲ្យលោកគ្រូទូន្មានខ្លះនោះឯង , មានការអីសូមមានប្រសាសន៍មកចុះ ។

- បាទ ! ក្រុមបក្សយើងបានប្រព្រឹត្តអំពើខ្លះមិនត្រឹមត្រូវមែន , តែដើម្បីចិញ្ចឹមជីវិតគ្រួសារបងប្អូនយើងជាងពីរម៉ឺននាក់ យើងត្រូវបិទភ្នែកតាំងខ្លួនជាអ្នកកុនង័យមផ្នែកខាងទុច្ចរិតសិន ដោយមិនបាច់គោរពសុជីវធម៌ ឬ មនុស្សធម៌ចំពោះអ្នកណាឡើយ ។ ប៉ុន្តែ ... ចំពោះគូប្រពន្ធនៃបងប្អូនរួមក្រុមសុំលោកនាយមេត្តា ... មេត្តាកុំសូវរវីរវល់ពេក ដើម្បីចៀសវាងការប្រេះឆាក្នុងផ្ទៃក្រុម ។

ស៊ីផានកើតសេចក្ដីអៀនខ្មាសក្រហមមុខដល់គុម្ពត្រចៀក នឹកដល់យប់មួយដែលនាយត្រូវចានលបចូលបន្ទប់នាយ រកប្រហារនាយដោយចោទប្រកាន់ថា នាយបានទៅលួចប្រពន្ធគាត់ ។ មើលទៅរឿងនេះមានមែនទេតើ ! គិតយ៉ាងម៉េចទៅ ?

តៃហាស៊ីពោលបន្ត :

– ម្យ៉ាងទៀតលោកតាចិនមិនហួសបីជាជនចំឡែកណាស់ ហើយមានយុទ្ធសិល្បៈពូកែទៀតផង ។ លោកនាយក្រុមទាក់ទងនឹងចៅស្រីគាត់ដូច្នេះ លោតែថ្ងៃក្រោយលោកបោះបង់នាងទៅក្រុមយើងនឹងមានសត្រូវមួយទៀតហើយ ។

- ម៉េចលោកគ្រូថាខ្ញុំបោះបង់នាងចោល ?

ពៅហៃស៊ីញញឹម :

-ពេលដែលលោកនាយក្រុមកំពុងស្រឡាញ់នារីណាម្នាក់នោះ លោកតែងទុកដាក់នាងជាម្ចាស់ប្រមាត់ដូចខ្ទះឯង, ប៉ុន្តែលោកនាយមិនដែលស្រឡាញ់នាងមួយណាឲ្យបានយូរអង្វែងទេ ។ ចំពោះអ្នកនាងចឹងនេះ, ពុំមានរឿងសំពះផ្ទឹមជូនតាថែមទៀតណា ! ក្រែងពុំមិនបានសុខ . . . សូមលោកនាយក្រុមកុំចាញ់កលលោកតាចិនមិនហួសបី ។

- ចុះបើខ្ញុំបានសំពះជូនតាអាមួយនាងមែន, ក្មេងម៉េចទៅ ?

បាទ, កាលណោះលោកនាយនៅឈប់ជូនមិនសូវស្រឡះមុខមាត់, ប្រហែលលោកបាញ់ប៉ោកកញ្ចាស់ចឹងហើយ ។ គេមិនអាចយកជាការមែនទែនឡើយ ។

ស៊ីផានជ្រួញចិញ្ចើមស្ញុងគិត, ពៅហៃស៊ីតបថា :

- និយាយពន្យល់បានមួយក៏តែហើយត្រូវផ្អាកត្រឹមហ្នឹងសិនកុំឲ្យខូចការ ។

គ្រូពេទ្យដៃដែកបង្វែរការសន្ទនាទៅរឿងផ្សេងដោយប្រញាប់ថា:

- ចំណែក អស់លោកទាំងប្អូនក្រុមមកពីណាទៅដល់ស្រុកយើងភ្លាមក៏ពុយចុកក្រអឺតក្រទមគួរឲ្យញាញ់ ។ លុះឃើញនាយក្រុមស្រាប់តែគេហៅ " អ្នកមានគុណ " ហើយខ្ញុំស្ដាប់ដូចលោកបោកតែម្ដង ។

ត្បិតនៅតាមផ្លូវលោកស្រីការីសាន ហេនដ៏បានរៀបរាប់រឿងដែលស៊ីផានពាយបង្ក្រាបចោរមិនញញួស ប្អូនជួយស្រោចស្រង់ជីវិតគ្នីគ្នា គាត់ហ៊ានអង់អាចប្រាប់សមាជិកក្រុមឈានល្បួយហ៊ានក្បាលក្បាយអស់ហើយ ។

ពៅហៃស៊ីបន្ត :

- ពួកទាំងអស់នេះមិនពូកែខាងយុទ្ធសិល្ប៍ដូចលោកនាយក្រុមមែន, ប៉ុន្តែគេមានកេរ្តិ៍ឈ្មោះលេចឮពេញពិភពគុនដែរ, បើលោកនាយក្រុមមានគុណារើពួកគេមែនគួរឆ្លៀតឱកាសនេះ ទាក់ទាញគេឲ្យធ្វើការផ្ដល់ប្រយោជន៍ឲ្យយើងល្អជាង ។ បើគេដឹងរឿងលោកនាយក្រុមទាស់គុងហ្វាង លោកប្រាប់ថាគុងហ្វាងដកខ្លួនចេញពីក្រុមឈានល្បួពីពិភពគុនហើយ ។ ចំណែករឿងរ៉ាវទាំងអស់ដែលខ្ញុំបានដំណាលឲ្យស្ដាប់ម្សិលមិញលោកមិនបាច់ប្រាប់គេទេ នាំតែមានការរំខានឥតប្រយោជន៍ ។

ស៊ីផានងក់ក្បាល :

Khmer Story Lovers



- លោកគ្រូមានប្រសាសន៍ត្រូវណាស់ !

អ្នកទាំងពីរដើរកន្លងមួយសន្ទុះ ទើបតៃហេស៊ុយលូកបញ្ជីមួយពីក្នុងហោប៉ៅអាវប្រគល់ឲ្យស៊ីផាន បញ្ជីនេះសម្រាប់កត់ត្រាចំណូលចំណាយនៃក្រុមឈានល្អ មានតាំងពីសាខាណា ទទួលប្រាក់ ចុះផ្ទេរ សាខាណា ឲ្យយកប្រាក់ប៉ុន្មាន រកបានកម្រៃមួយខែៗបានប៉ុន្មាន, តែមាណពមើលឥតយល់ទាល់តែសោះ ។

ក្រុមឈានល្អពាក់មានគ្នាច្រើន ដើររកបោកអ្នកមានក្នុងស្រុកដើម្បីជំរិតយកប្រាក់កាសនិងកេស្តិការ គ្រប់យ៉ាងចិញ្ចឹមជីវិតសមាជិកខ្លួន ។ ក្រុមបក្សពួកខ្មែរតែងតែឲ្យបង់ឲ្យក្រុមឈានល្អជួយការពារកិច្ចការ ស្ហួយសាកាសមកឲ្យរាល់ខែរាល់ឆ្នាំ ។ ស៊ីផានយល់ថាក្រុមឈានល្អមានការៈដូចមេចោរកំណាច នៅស្រុកចាំតែយកផលប្រយោជន៍ពីអ្នកផងដទៃ ។ នាយមិនពេញចិត្តទេ ជាមួយតៃហេស៊ុយបាន ។

រាត្រីនោះក្រុមឈានល្អបានរៀបពិធីជប់លៀងមួយជាកិត្តិយសដល់អ្នកគ្នា ហានមកពីដំបន់ណាកុង ៖ គេអញ្ជើញហានយីហ្វមិនការសានលានដ៏អស្ចារ្យកន្លែងខ្ពស់ ស៊ីផាន,តៃហេស៊ុយ និងទីកុងអង្គុយខាងក្រោមអមជុំវិញ ។ ហានយីហ្វលើកកែវស្រាក្រហមហើយគាត់ថ្លែងអំណរគុណចំពោះម្ចាស់ផ្ទះ ដោយពោលសរសើរ ៗ :

- លោកមានគុណពេកដែលជ្រោមជ្រែងយុទ្ធសិល្បៈ ខ្ញុំនឹងប្រើការរៀបចំក្រុមឈានល្អឲ្យរីកចំរើនសម្បូរណាស់, មើលទៅលោកបងកុងហានសប្បាយពេញចិត្តនឹងលោកនាយក្រុមណាស់...

តៃហេស៊ុយឆ្លើយជំនួស:

- អូ, ពេលនេះប្រហែលលោកនាយក្រុមចាស់យើងកំពុងស្ងួតក្រពុំក្រោមផ្កាឥតមិនតឹងនាយលេងកិច្ចការក្នុងក្រុមទៀតទេ ។ លោកនៅយ៉ាងសប្បាយស្ងាត់ដូច្នេះ យើងខ្ញុំម្ដេចនឹងហ៊ានយករឿងកំប៉ុកកំប៉ុកទៅរំខានលោក ?

ហានយីហ្វរិះគិតពាក្យពេចន៍មកឆ្លើយសួរដំណឹងពីលោកកុងហានទៀត ស្រាប់តែឃើញនាយគ្រូគេងខាងផ្នែកខាងកំណាចកំពែងស្រែកហាមមករស្រែកក្រចៀកតៃហេស៊ុយ ។ គ្រូពេទ្យងក់ក្បាលសើចញញឹមពោលថា :

-ប្រសើរណាស់, ប្រសើរណាស់ !

ហើយគាត់ងាកទៅប្រាប់ស៊ីផាន :

-ជំរាបប្រសាសន៍លោកនាយក្រុម, ក្រោយពីចាប់បានសិស្សក្អទឹកកកប៉ុន្មាននាក់យកឃុំឃាំងនោះ, ពួកគេបានមនុស្សមកជួយសម៉ៀមណាស់, ប៉ុន្តែលួចនាំមិនបានត្រូវខាតបង់ផ្លែទៀត ! អម្បាញ់មិញយើងចាប់បានពីរនាក់ ។

ស៊ីផានភ្ញាក់ព្រើតសួរ :

- ហ្អ ! យើងចាប់បានសិស្សក្អទឹកកកទៀតហើយ ?

ពៃហាស៊ីសេីច :

កាលដែលលោកនាយក្រុមនិងប៉ាយវ៉ាន់ផានចាកចេញពីក្រុមយើងទៅនោះ យើងព្រួយបារម្ភជាខ្លាំងដោយខ្លាចលោកនាយក្រុមស្លូតត្រង់ពេកត្រឡប់ជាចាញ់កលឧបាយគេ...

ពៃហាស៊ីមិនហ៊ានពោលចំពោះមុខអ្នកកាហានទៅលាវតុងថា នាយក្រុមឈានលួត្រូវប៉ាយវ៉ាន់វ៉េនចាប់នាំទៅបានជាពោលពាក្យបន្ទុះ ។

គាត់បន្តសេចក្តីថា :

- ពួកយើងខំប្រមូលគ្នាស៊ើបសួរដំណឹងលោកនាយក្រុម ល់រវាងកញ្ញាសមួយនោះ យើងប្រើកលល្បិចបន្តិចបន្តួចចាប់បានតាំងអស់មកឃុំទុក ។ យើងស្គាល់គេប៉ាយវ៉ាន់វ៉េនម្នាក់ប៉ុណ្ណោះ តាចិតាំងផ្តាក់វៃហើយទាំសណាស់ដោះដៃវត់បាត់ !

ទីងគុងស្តាប់យូរហើយក៏សួរគាត់ :

- អ្នកនាំងហួវ៉ាន់ជ័យយ៉ាងម៉េចទៅហើយ ?

ពៃហាស៊ីគប :

- ទេ ! ពួកសិស្សក្អទឹកកកដែលយើងចាប់បានលើកមុនមានចំនួនប្រាំពីរនាក់, អ្នកនាំងឃើញផ្ទាល់ភ្នែកដែរតើ !

ហ្វានយីហ្វេងនិងគ្នាមានការភ្ញាក់ផ្អើលជាខ្លាំង ដោយឥតនឹកស្មានថាក្រុមក្អទឹកកកពូកែល្បិចល្បាញពេញពិកពត្តុនមកចាញ់កលក្រុបឈាលឲ្យគេចាប់បានដោយងាយយ៉ាងនេះសោះ ត្រូវកោម៉ាសមុខមែន!

(នៅមានត)

---

ដំកល់ទុកតាមលេខ ៣៨០ ចុះថ្ងៃទី ៩ ៦ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers